(Khmer)

# ការវាយតម្លៃអំពីតម្រូវការឆ្នាំ៖ ការស្ទង់មតិ

សូមអរគុណសម្រាប់ការចូលរួមក្នុងការស្ទង់មតិនេះ។ ការឆ្លើយតបរបស់អ្នកនឹងជួយឱ្យទីភ្នាក់ងារមនុស្សចាស់ក្នុងតំបន់ (Area Agency on Aging, AAA) របស់យើងយល់ពីតម្រូវការរបស់មនុស្សចំណាស់ និងអ្នកថែទាំរបស់ពួកគាត់នៅក្នុងសហគមន៍របស់យើង។ ការឆ្លើយតបរបស់អ្នកនឹងត្រូវបានរក្សាទុកជាសម្ងាត់ ហើយនឹងមិនត្រូវបានចែករំលែកនៅខាងក្រៅ AAA របស់អ្នក និងការិយាល័យប្រតិបត្តិផ្នែកកិច្ចការមនុស្សចាស់ (Executive Office of Elder Affairs) ឡើយ។

**1. តើអ្នកកំពុងបំពេញការស្ទង់មតិនេះ (a) តាងនាមឱ្យខ្លួនឯងជាមនុស្សវ័យចំណាស់ ឬ (b) ក្នុងនាមជាអ្នកថែទាំមនុស្សវ័យចំណាស់ដែលអ្នកមើលថែទាំ *(អ្នកទទួលការថែទាំរបស់អ្នក)* ឬ?**

- ❑ ខ្លួនឯង → *សូមរំលងទៅសំណួរទី 3 នៅទំព័របន្ទាប់*
- ❑ អ្នកថែទាំ

STOP *មានតែអ្នកថែទាំប៉ុណ្ណោះដែលគួរបំពេញ សំណួរទី 2។ ប្រសិនបើអ្នកបំពេញក្នុងនាមខ្លួនរបស់អ្នក សូមរំលងទៅសំណួរទី 3។*

**2. តើជំនួយជាក់លាក់អ្វីខ្លះដែលអាចជួយអ្នកបាន ក្នុងនាមជាអ្នកថែទាំ?**
*(ជ្រើសរើសចម្លើយទាំងអស់ដែលពាក់ព័ន្ធ)*

- ❑ ការថែទាំសម្រាប់ការសម្រាកលំហែ៖ ជំនួយបណ្ដោះអាសន្នដើម្បីសម្រាកពីទំនួលខុសត្រូវថែទាំ។
- ❑ ក្រុមគាំទ្រ៖ ចូលរួមក្នុងក្រុមគាំទ្រសម្រាប់ការគាំទ្រផ្នែកផ្លូវអារម្មណ៍ និងផ្នែកសង្គម។
- ❑ ជំនួយផ្នែកហិរញ្ញវត្ថុ៖ ជំនួយលើថ្លៃចំណាយទាក់ទងនឹងការថែទាំ។
- ❑ ការបណ្ដុះបណ្ដាល និងការអប់រំ៖ ការបណ្ដុះបណ្ដាលអំពីជំនាញថែទាំ ការថែទាំអ្នកជំងឺវង្វេងស្មារតី និងព័ត៌មានអំពីការគ្រប់គ្រងស្ថានភាពជំងឺជាក់លាក់ណាមួយ។
- ❑ ជំនួយផ្នែកវេជ្ជសាស្ត្រ៖ ជំនួយលើការគ្រប់គ្រងតម្រូវការវេជ្ជសាស្ត្ររបស់អ្នកទទួលការថែទាំ រួមទាំងការទទួលបានគ្រូពេទ្យជំនាញថែទាំសុខភាព។
- ❑ ជំនួយផ្នែកច្បាប់៖ ជំនួយលើបញ្ហាផ្លូវច្បាប់ទាក់ទងនឹងការថែទាំ ដូចជាលិខិតប្រគល់សិទ្ធិអំណាច និងភាពជាអាណាព្យាបាល។
- ❑ សេវាមធ្យោបាយធ្វើដំណើរ៖ ចូលប្រើមធ្យោបាយធ្វើដំណើរសម្រាប់ការណាត់ជួបវេជ្ជសាស្ត្ររបស់អ្នកទទួលការថែទាំ និងតម្រូវការផ្សេងៗ។
- ❑ ការកែលម្អផ្ទះសំបែង៖ ជំនួយលើការធ្វើឱ្យផ្ទះសំបែងកាន់តែមានសុវត្ថិភាព និងកាន់តែមានភាពងាយស្រួលចេញចូលប្រើប្រាស់សម្រាប់អ្នកទទួលការថែទាំ។
- ❑ ការសម្របសម្រួលការថែទាំ៖ ជំនួយលើការសម្របសម្រួលការថែទាំ និងសេវាកម្មសម្រាប់អ្នកទទួលការថែទាំ។
- ❑ ជំនួយផ្នែកសុខភាពផ្លូវចិត្ត៖ ចូលប្រើសេវាសុខភាពផ្លូវចិត្តសម្រាប់សុខុមាលភាពផ្ទាល់ខ្លួនរបស់អ្នកថែទាំ។
- ❑ ជំនួយបច្ចេកវិទ្យា៖ ជំនួយលើការប្រើប្រាស់បច្ចេកវិទ្យាដើម្បីពិនិត្យតាមដាន និងថែទាំអ្នកទទួលការថែទាំ។

- ❑ ព័ត៌មាន និងធនធាន៖ ទទួលបានព័ត៌មាន និងធនធានអំពីការថែទាំ និងសេវាកម្មដែលមាន។
- ❑ សេវាកម្មថែទាំតាមផ្ទះ៖ ចូលប្រើសេវាកម្មថែទាំតាមផ្ទះដែលមានជំនាញដើម្បីជួយដល់កិច្ចការថែទាំ។
- ❑ ជំនួយអាហារូបត្ថម្ភ៖ ជំនួយលើការរៀបចំផែនការ និងការរៀបចំចំណីអាហារសម្រាប់អ្នកទទួលការថែទាំ។
- ❑ ជំនួយតុល្យភាពរវាងការងារនិងជីវិត៖ ធនធានដើម្បីជួយធ្វើឱ្យទំនួលខុសត្រូវលើការថែទាំមានតុល្យភាពជាមួយនឹងការងារ និងជីវិតផ្ទាល់ខ្លួន។




ធនធានសហគមន៍៖ ព័ត៌មានអំពីធនធានសហគមន៍ និងសេវាកម្មដែលមានសម្រាប់អ្នកថែទាំ។
ផ្សេងទៀត (សូមបញ្ជាក់)៖ ___________________

*ប្រសិនបើអ្នកកំពុងបំពេញក្នុងនាមជាអ្នកថែទាំ សូមបំពេញការស្ទង់មតិផ្នែកដែលនៅសល់សម្រាប់បុគ្គលដែលអ្នកផ្តល់ការថែទាំ (អ្នកទទួលការថែទាំ) រួមទាំងព័ត៌មានប្រជាសាស្ត្ររបស់ពួកគាត់។*

**3. តម្រូវការ**

*សូមពិនិត្យមើលបញ្ជីខាងក្រោម ហើយជ្រើសរើសតម្រូវការ (របស់អ្នកទទួលការថែទាំ) ដែលសំខាន់បំផុតរបស់អ្នក ទាក់ទងនឹងវ័យចំណាស់។ ឧទាហរណ៍នៅក្រោមប្រភេទនីមួយៗមិនរួមបញ្ចូលឧទាហរណ៍ដែលអាចធ្វើបានទាំងអស់ទេ ដូច្នេះអ្នកអាចជ្រើសរើសប្រភេទមួយ ទោះបីជាអ្នកមិនឃើញតម្រូវការ ជាក់លាក់ (របស់អ្នកទទួលការថែទាំ) របស់អ្នក ត្រូវបានរាយក្នុងបញ្ជីក៏ដោយ។*

*ជ្រើសរើសតម្រូវការទាំងអស់ដែលសំខាន់សម្រាប់អ្នក (អ្នកទទួលការថែទាំ)៖*

- ❑ ការចូលប្រើសេវាកម្ម
  - ឧទាហរណ៍ ការទទួលបានជំនួយទាក់ទងនឹងអត្ថប្រយោជន៍កម្មវិធី ជំនួយអាហារូបត្ថម្ភបន្ថែម (Supplemental Nutrition Assistance Program, SNAP)/អាហារ ព្រមទាំងសេវាហិរញ្ញវត្ថុ និងការដាក់ពាក្យសុំធានារ៉ាប់រងសុខភាព។
- ❑ ការថែទាំសុខភាពដែលមានតម្លៃសមរម្យ
  - ឧទាហរណ៍ ការទទួលបានសេវាសុខភាពដែលមានតម្លៃសមរម្យ ការធានារ៉ាប់រង និងការគ្រប់គ្រងថ្លៃចំណាយឱសថមានវេជ្ជបញ្ជា។
- ❑ ការទទួលបានការថែទាំសុខភាព
  - ឧទាហរណ៍ ការស្វែងរកវេជ្ជបណ្ឌិត ការទទួលបានសេវាសុខភាព ការចូលរៀនក្នុងថ្នាក់បង្ការការដួល ការស្វែងរកជម្រើសថ្នាំជំនួស និងការទទួលបានការជួបពិនិត្យដល់ផ្ទះ។
- ❑ លំនៅឋានដែលមានតម្លៃសមរម្យ
  - ឧទាហរណ៍ ការស្វែងរកលំនៅឋានដែលមានតម្លៃសមរម្យ ការមានឈ្មោះក្នុងបញ្ជីរង់ចាំសម្រាប់ផ្ទះយូនីតដែលបានផ្តល់ឧបត្ថម្ភធន និងការទទួលបានជំនួយសម្រាប់ការជួល។
- ❑ ការរៀបចំលំនៅឋានដែលងាយស្រួលចេញចូលរស់នៅនិងការថែទាំ
  - ឧទាហរណ៍ ការស្វែងរកលំនៅឋានដែលងាយស្រួលចេញចូលរស់នៅ និងជំនួយក្នុងការថែទាំនិងជួសជុលលំនៅឋាន។

- ជំនួយតាមផ្ទះសម្រាប់ការរស់នៅដោយឯករាជ្យ
  - ឧទាហរណ៍ ជួយដល់មនុស្សចាស់នៅនឹងកន្លែង ជំនួយលើសកម្មភាពរស់នៅប្រចាំថ្ងៃ (ដូចជា ការងូតទឹក ការប្រើប្រាស់បង្គន់ ការស្លៀកពាក់ ការពិសាអាហារ ការដើរ និងការតុបតែងខ្លួន) ការថែទាំផ្ទះ និងទ្រព្យសម្បត្តិ (ការកាយព្រិលចេញ ការថែទាំស្មៅ ការកាយស្លឹកឈើចេញ) ការកែលម្អលំនៅឋាន កិច្ចការទូទៅ បញ្ហានៃលំនឹងនិងចលនារាងកាយ និងការទទួលបានឧបករណ៍ដែលចាំបាច់។
- សេវាថែទាំនិងការគាំទ្ររយៈពេលវែង
  - ឧទាហរណ៍ ការទទួលបានសេវាថែទាំតាមផ្ទះ ការទទួលបានបុគ្គលិកកាន់តែប្រសើរឡើងនៅមណ្ឌលថែទាំរយៈពេលវែង ការគាំទ្រនៅក្នុងទីប្រជុំជនជនបទ និងការបង្កើនការគ្រប់គ្រងករណី។
- ជំនួយគ្រប់គ្រងការចំណាយផ្សេងៗ
  - ឧទាហរណ៍ ជំនួយលើការចំណាយដែលមិនទាក់ទងនឹងលំនៅឋាន និងមិនពាក់ព័ន្ធនឹងការថែទាំសុខភាពដូចជា ពន្ធ សេវាសាធារណៈ (ថ្លៃទឹក ភ្លើង ឧស្ម័ន) និងចំណីអាហារ។
- សេវាផ្លូវច្បាប់
  - ឧទាហរណ៍ ការស្វែងរកទីប្រឹក្សាផ្លូវច្បាប់ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងប្រាក់ចំណូល និងអត្ថប្រយោជន៍សាធារណៈ ការថែទាំសុខភាព ការថែទាំរយៈពេលវែង អាហារូបត្ថម្ភ លំនៅឋាន សេវាសាធារណៈ (ទឹក ភ្លើង ឧស្ម័ន) សេវាគាំពារ ការរំលោភបំពាន ការទុកចោលដោយមិនយកចិត្តទុកដាក់ ការរើសអើងអាយុ និងការការពារភាពជាអាណាព្យាបាល។
- ជំនួយផ្នែកសុខភាពផ្លូវចិត្ត និងអាកប្បកិរិយា
  - ឧទាហរណ៍ ការស្វែងរកថ្នាក់រៀននិងការអប់រំសុខភាពផ្លូវចិត្ត ការប្រឹក្សាយោបល់ ជំនួយទាក់ទងនឹងជំងឺធ្លាក់ទឹកចិត្ត ការថប់បារម្ភ និងភាពតានតឹង ការដោះស្រាយវិបត្តិដោយសារការប្រើប្រាស់គ្រឿងញៀននិងគ្រឿងស្រវឹង។
- ជំនួយអាហារូបត្ថម្ភ
  - ឧទាហរណ៍ ការទទួលបានអាហារដែលធ្វើឱ្យមានសុខភាពល្អ ជំនួយលើការរៀបចំអាហារ ជំនួយក្នុងការដឹកជញ្ជូន និងការដោះស្រាយបញ្ហាអសន្តិសុខស្បៀងអាហារ។
- សុវត្ថិភាព និងសន្តិសុខ
  - ឧទាហរណ៍ ការកែលម្អលំនៅឋានសម្រាប់បង្ការការដួលនិងលំនឹងរាងកាយ ការទប់ទល់នឹងការរំលោភបំពាន ការកេងប្រវ័ញ្ច ការធ្វើបាប សុវត្ថិភាពសាធារណៈ និងសុវត្ថិភាពសហគមន៍។
- ការទទួលបាននិងចូលប្រើប្រាស់មធ្យោបាយធ្វើដំណើរ
  - ឧទាហរណ៍ ការស្វែងរកមធ្យោបាយធ្វើដំណើរសម្រាប់ការណាត់ជួប ឬសកម្មភាពសង្គម ឱកាសធ្វើដំណើរតាមរថយន្តក្រុង/ធ្វើដំណើររួមគ្នាកាន់តែច្រើនជាងមុន ជំនួយពាក់ព័ន្ធនឹងមធ្យោបាយធ្វើដំណើរសាធារណៈ និងមធ្យោបាយធ្វើដំណើរនៅថ្ងៃចុងសប្តាហ៍។
- ការអភិវឌ្ឍកម្លាំងពលកម្ម

- ឧទាហរណ៍ ការស្វែងរកការងារ ឱកាសការងារដែលអាចបត់បែនបាន ឱកាសបង្កើនជំនាញវិជ្ជាជីវៈ និងការងារផ្តល់ប្រាក់កម្រៃច្រើន។

- ❑ ជំនួយដោះស្រាយភាពឯកោក្នុងសង្គម
  - ឧទាហរណ៍ ការស្វែងរកគ្នាក់ដរ ការទទួលបានបច្ចេកវិទ្យាដែលមានតម្លៃសមរម្យ កម្មវិធីតាមទូរសព្ទ/អ៊ីនធឺណិត ការភ្ជាប់ទំនាក់ទំនងជាប្រចាំ និងការគាំទ្រផ្លូវការ និងក្រៅផ្លូវការ។
- ❑ ឱកាសសម្រាប់លំហែកាយ ការកម្សាន្ត និងការចូលរួមក្នុងសង្គម
  - ឧទាហរណ៍ ការស្វែងរក និងការចូលរួមក្នុងសកម្មភាពសង្គម ព័ត៌មានអំពីកម្មវិធីផ្សេងៗ អត្រាតម្លៃដែលបានបញ្ចុះថ្លៃនៅតាមទីតាំង/សារមន្ទីរ កន្លែងខាងក្រៅផ្ទះសម្រាប់មនុស្សចាស់ និងការចូលរួមក្នុងសង្គមនៅតាមសហគមន៍ជនបទ។
- ❑ ការចូលរួមរបស់ប្រជាពលរដ្ឋ / ឱកាសសម្រាប់អ្នកស្ម័គ្រចិត្ត
  - ឧទាហរណ៍ ការស្វែងរកឱកាសស្ម័គ្រចិត្ត ការចូលរួមសហគមន៍មនុស្សចាស់ និងការចូលរួមសកម្មភាពនៅក្នុងសង្កាត់។
- ❑ ឱកាសរៀនសូត្រនិងអភិវឌ្ឍន៍
  - ឧទាហរណ៍ ការស្វែងរកកម្មវិធីអប់រំ ការរៀនជំនាញថ្មីៗ (ដូចជា ការប្រើប្រាស់អ៊ីមែល អ៊ីនធឺណិត កម្មវិធីទូរសព្ទ ជាដើម) និងការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល។
- ❑ ការបន្តនៅមានសកម្មភាព / ការលើកកម្ពស់សុខុមាលភាព
  - ឧទាហរណ៍ ការស្វែងរកថ្នាក់រៀនអំពីមនុស្សចាស់ដែលមានសុខភាពល្អ ព័ត៌មានអំពីសុខុមាលភាពផ្លូវកាយ កម្មវិធីហាត់ប្រាណ ថ្នាក់ហាត់ប្រាណសម្រាប់មនុស្សវ័យចំណាស់ និងការគាំទ្រសម្រាប់អ្នកថែទាំ។
- ❑ ដោះស្រាយអាកប្បកិរិយាអវិជ្ជមានដោយផ្អែកលើអាយុ និងការរើសអើងអាយុ
  - ឧទាហរណ៍ ការបង្ការទស្សនៈយល់ឃើញអវិជ្ជមាន អាកប្បកិរិយាប្រព្រឹត្តដោយភាពលម្អៀង និងការរើសអើងដោយផ្អែកលើអាយុ។
- ❑ ការជំនះឧបសគ្គភាសា/ការទំនាក់ទំនង
  - ឧទាហរណ៍ ការស្វែងរកសេវាបកប្រែផ្ទាល់មាត់/បកប្រែឯកសារ ការស្វែងរកព័ត៌មានអំពីសេវាកម្ម និងធនធាននានាជាភាសាផ្សេងទៀត និងការចូលរៀនថ្នាក់ភាសាអង់គ្លេសជាភាសាទីពីរ (English as a Second Language, ESL)។
- ❑ ការគាំទ្រ LGBTQIA+
  - ឧទាហរណ៍ ការស្វែងរកអ្នកផ្តល់សេវាដែលយល់ដឹងអំពី ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ពីរភេទ (ទាំងបុរសនិងស្ត្រី) អ្នកផ្លាស់ប្តូរយេនឌ័រ អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង/អ្នកកំពុងស្វែងយល់ពីអត្តសញ្ញាណយេនឌ័រខ្លួនឯង អន្តរភេទ (បុគ្គលដែលកើតមកមានអវយវៈភេទស្រីផងប្រុសផង) អ្នកដែលមិនមានចំណង់ផ្លូវភេទ/សម្ពន្ធមិត្ត ក៏ដូចជាបញ្ហាអត្តសញ្ញាណផ្សេងទៀត ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និង ការទទួលបានការគាំទ្រដើម្បីដោះស្រាយបញ្ហាការប្រព្រឹត្តចំពោះគ្នាដោយលម្អៀង។
- ❑ ការគាំទ្រផ្នែកស្មារតី

  - ឧទាហរណ៍ ការស្វែងរកសកម្មភាពដោយផ្អែកលើភាពសុទ្ធចិត្ត ការបង្កើតឱកាសសម្រាប់ការលូតលាស់ផ្នែកស្មារតី និងការស្វែងរកដំណោះស្រាយចូលរួមនៅពេលមិនមានសេវាដោយផ្ទាល់។
- ❑ ផ្សេងទៀត (សូមបញ្ជាក់)៖ _______________

**4. ការដាក់ចំណាត់ថ្នាក់តម្រូវការ**

*សូមដាក់ចំណាត់ថ្នាក់តម្រូវការខ្ពស់ចំនួន 3 ដែលអ្នកបានជ្រើសរើសក្នុងបញ្ជីខាងលើ ដោយផ្អែកលើសារៈសំខាន់របស់វាចំពោះអ្នក (អ្នកទទួលការថែទាំ)។*

*ដើម្បីចាត់ថ្នាក់តម្រូវការ សូមត្រឡប់ទៅបញ្ជីសំណួរទី 3 ដែលអ្នកទើបតែបានបំពេញ ហើយសរសេរ លេខ '1' នៅជាប់នឹងតម្រូវការដែលសំខាន់បំផុតសម្រាប់អ្នក (អ្នកទទួលការថែទាំ) លេខ '2' នៅជាប់នឹងតម្រូវការសំខាន់បំផុតទីពីរ និងលេខ ' 3' នៅជាប់នឹងតម្រូវការសំខាន់បំផុតទីបី។*

**5. តើចំណុចខាងក្រោមមួយណាដែលទាក់ទងនឹងអ្នក (អ្នកទទួលការថែទាំ)?**

*(ជ្រើសរើសចម្លើយទាំងអស់ដែលទាក់ទង)*

- ❑ ជួបប្រទះបញ្ហារំលោភបំពាន ការទុកចោលដោយមិនយកចិត្តទុកដាក់ ឬការកេងប្រវ័ញ្ច
- ❑ រស់នៅដោយមានជំងឺអាល់ហ្សៃមឺរ (ភ្លេចភ្លាំង) ឬជំងឺវង្វេងស្មារតី
- ❑ ជួបប្រទះបញ្ហាការចងចាំ ឬការគិត
- ❑ ត្រូវការទទួលបានសកម្មភាពវប្បធម៌ ឬសង្គម (ដូចជាព្រឹត្តិការណ៍វប្បធម៌ សេវាសាសនា ក្រុមសង្គម)
- ❑ រស់នៅជាមួយនឹងការបាត់បង់ការមើលឃើញ
- ❑ រស់នៅជាមួយនឹងការបាត់បង់ការស្តាប់
- ❑ រស់នៅដោយមានពិការភាពរាងកាយ (រួមមាន ការចុះខ្សោយចលនារាងកាយ និងបញ្ហាសុខភាពផ្លូវកាយរ៉ាំរ៉ៃ)
- ❑ មានសុខភាពទន់ខ្សោយ ឬទ្រុឌទ្រោម
- ❑ ជាជីដូនជីតាកំពុងចិញ្ចឹមបីបាច់ចៅៗ
- ❑ មានកង្វល់ផ្ទះសំបែង (ដូចជា បញ្ហាការជួលដែលមានតម្លៃសមរម្យ លក្ខខណ្ឌរស់នៅមិនមានសុវត្ថិភាព)
- ❑ មានអារម្មណ៍ឯកោ ឬដាច់ឆ្ងាយពីគេជាញឹកញាប់ (ដូចជា ទំនាក់ទំនងសង្គមមានកម្រិត កង្វះមិត្តភាព)
- ❑ ត្រូវការសេវាផ្លូវច្បាប់ (ដូចជាជំនួយលើបញ្ហាលំនៅឋាន អត្ថប្រយោជន៍រដ្ឋាភិបាល លិខិតប្រគល់សិទ្ធិអំណាច និងដំបូន្មានផ្នែកច្បាប់)
- ❑ ជាផ្នែកនៃសហគមន៍ LGBTQIA+
- ❑ មានបញ្ហាសុខភាពផ្លូវចិត្ត ឬផ្លូវអារម្មណ៍ (ដូចជា ជំងឺថប់បារម្ភ ជំងឺធ្លាក់ទឹកចិត្ត ភាពតានតឹង)
- ❑ ត្រូវការជំនួយផ្នែកចំណីអាហារ ឬអាហាររូបត្ថម្ភ (ដូចជា ការពិបាកក្នុងការធ្វើម្ហូប ត្រូវការការដឹកជញ្ជូនអាហារ)
- ❑ រស់នៅក្នុងតំបន់ជនបទ (ការចូលប្រើសេវាកម្មមានកំណត់ ទីតាំងដាច់ស្រយាល)
- ❑ មានតម្រូវការទាក់ទងនឹងការងារ ឬមុខរបរ (ដូចជា ជំនួយស្វែងរកការងារ ការសម្របសម្រួលនៅកន្លែងធ្វើការ)

- ❑ ផ្សេងទៀត (សូមបញ្ជាក់)៖ ____________________

**6. តើអ្នក *(អ្នកទទួលការថែទាំ)* រស់នៅក្នុងទីប្រជុំជន/ទីក្រុងណា?**

________________________________________

**7. តើអ្នក *(អ្នកទទួលការថែទាំ)* មានអាយុប៉ុន្មាន?**

________________________________________

**8. តើអ្នក *(អ្នកទទួលការថែទាំ)* មានអត្តសញ្ញាណយេនឌ័រដូចម្តេចដែរ?**
*(ជ្រើសរើសចម្លើយទាំងអស់ដែលពាក់ព័ន្ធ)*

- ❑ បុរស
- ❑ ស្ត្រី
- ❑ មិនមានភេទជាក់លាក់មួយ យេនឌ័រដែលគ្មានការបញ្ជាក់ អ្នកមិនកំណត់យេនឌ័រខ្លួនឯង
- ❑ មិនដឹង
- ❑ មិនមានរាយនៅខាងលើ (សូមបញ្ជាក់)៖________________________
- ❑ សុំមិននិយាយ

**9. តើអ្នក *(អ្នកទទួលការថែទាំ)* ជាជនជាតិ ឬជាតិពន្ធុអ្វី?** *(ជ្រើសរើសចម្លើយទាំងអស់ដែលពាក់ព័ន្ធ។ បញ្ជាក់៖ អ្នកអាចរាយការណ៍លើសពីមួយក្រុមបាន។)*

- ❑ ជនជាតិស្បែកស
- ❑ ជនជាតិស្បែកខ្មៅ ឬជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក
- ❑ ជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កា
- ❑ ជនជាតិអាស៊ី
- ❑ ជនជាតិហាវ៉ៃដើម ឬអ្នកកោះប៉ាស៊ីហ្វិកផ្សេងទៀត
- ❑ មជ្ឈិមបូព៌ា ឬជនជាតិអាហ្វ្រិកខាងជើង
- ❑ ជនជាតិដើមអេស្ប៉ាញ ឬអាមេរិកឡាទីន
- ❑ ជាតិសាសន៍ ឬជាតិពន្ធុមួយចំនួនផ្សេងទៀត៖ ________________________

**10. តើអ្នក *(អ្នកទទួលការថែទាំ)* និយាយភាសាមួយទៀតផ្សេងពីភាសាអង់គ្លេសពេលនៅផ្ទះមែនទេ?**

- ❑ បាទ/ចាស
- ❑ ទេ

**11. ប្រសិនបើ បាទ/ចាស តើភាសានោះជាភាសាអ្វី?**

- ❑ អេស្ប៉ាញ
- ❑ ព័រទុយហ្គាល់
- ❑ ចិន (រួមទាំង កុកងឺ និង កាតាំង)
- ❑ បារាំង
- ❑ ក្រេអូល ហៃទី
- ❑ វៀតណាម

- ❑ អ៊ីតាលី
- ❑ រុស្ស៊ី
- ❑ អារ៉ាប់
- ❑ កូរ៉េ
- ❑ ផ្សេងទៀត៖ ______________________________

**12. តើអ្នក *(អ្នកទទួលការថែទាំ)* និយាយភាសាអង់គ្លេសបានល្អកម្រិតណា?**

- ❑ ល្អណាស់
- ❑ ល្អ
- ❑ មិនសូវល្អទេ
- ❑ មិនល្អទាល់តែសោះ

**13. តើអ្នក *(អ្នកទទួលការថែទាំ)* មានប្រាក់ចំណូលគ្រួសារប្រចាំឆ្នាំតិចជាងចំនួន $20,000 ឬ?**
*(អាចមិនឆ្លើយបាន)*

- ❑ បាទ/ចាស
- ❑ ទេ
- ❑ សុំមិនឆ្លើយ

**14. តើអ្នក *(អ្នកទទួលការថែទាំ)* បច្ចុប្បន្នជាសមាជិកគម្រោង MassHealth ឬ?**

- ❑ បាទ/ចាស
- ❑ ទេ
- ❑ ខ្ញុំមិនដឹងទេ

**15. តើអ្នក *(ឬអ្នកទទួលការថែទាំ)* មានមតិចូលរួម ឬគំនិតណាមួយចង់ចែករំលែកជាមួយពួកយើងឬទេ?**

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

________________________________________________________________________

**សម្រាប់ព័ត៌មាន ធនធានបន្ថែម ឬដើម្បីភ្ជាប់ទៅទីភ្នាក់ងារមនុស្សចាស់ក្នុងតំបន់ (AAA) របស់អ្នក សូមទាក់ទងទៅ MassOptions លេខ 800-243-4636 ឬចូលមើលគេហទំព័ររបស់ពួកគេ តាមតំណ www.massoptions.org។**